# ព្រះរាជក្រឹត្យ

**នស/រកត/១១១៧/១១០៧**

## ស្តីពី
## របបសោធននិវត្តន៍ និងប្រាក់ឧបត្ថម្ភមរណភាព
## នៃសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## យើង
## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ព្រះរាជក្រឹត្យនេះ មានគោលបំណងកំណត់អំពីរបបសោធននិវត្តន៍ និងប្រាក់ឧបត្ថម្ភមរណភាពនៃសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីផ្តល់ជូនសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅពេលចប់អាណត្តិដល់អាយុចូលនិវត្តន៍ដែលមិនត្រូវបានជ្រើសតាំងបន្តទៀត និងសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលបានទទួលមរណភាពនៅក្នុងអាណត្តិ និងនិវត្តន៍ជនដែលបានទទួលមរណភាព។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា ២.-**

ព្រះរាជក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

## ជំពូកទី២
## ប្រាក់សោធននិវត្តន៍

**មាត្រា ៣.-**

សមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទទួលប្រាក់សោធននិវត្តន៍បាន លុះត្រាតែបានបំពេញលក្ខខណ្ឌ ដូចខាងក្រោម៖

- ជាសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងអាណត្តិមួយ ឬច្រើន គិតចាប់ពីឆ្នាំ១៩៩៨ មក
- មានអាយុចាប់ពី ៦០ ឆ្នាំឡើង
- មិនបានទទួលប្រាក់សោធននិវត្តន៍ពីស្ថាប័នណាមួយរបស់រដ្ឋទេ
- យល់ព្រមបោះបង់ប្រាក់សោធននិវត្តន៍ក្រសួង ស្ថាប័នណាមួយ បើមាន
- ត្រូវធ្វើពាក្យសុំចូលនិវត្តន៍

**មាត្រា ៤.-**

ប្រាក់សោធននិវត្តន៍ប្រចាំខែរបស់និវត្តជនម្នាក់ៗ ត្រូវគណនាតាមសន្ទស្សន៍ ដូចមានចែងក្នុងមាត្រា ៥ នៃព្រះរាជក្រឹត្យនេះ ផ្អែកលើប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់យ៉ាង ក្នុងរយៈពេលមួយឆ្នាំនៃឆ្នាំណាមួយ ដែលមានចំនួនទឹកប្រាក់អតិបរមា កំណត់ស្មើ ១០០% (មួយរយភាគរយ)។

**មាត្រា ៥.-**

ប្រាក់សោធននិវត្តន៍ប្រចាំខែ ត្រូវកំណត់ដោយផ្អែកលើរយៈពេលបំពេញការងារដូចតទៅ៖

- ពី ១ ឆ្នាំ ដល់ ៣ ឆ្នាំ ទទួលបានសន្ទស្សន៍ ០,៥%
- លើសពី ៣ ឆ្នាំ ដល់ក្រោម ៦ ឆ្នាំ ទទួលបានសន្ទស្សន៍ ១%
- ពី ៦ ឆ្នាំ ដល់ក្រោម ១១ ឆ្នាំ ទទួលបានសន្ទស្សន៍ ២%
- ពី ១១ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ ទទួលបានសន្ទស្សន៍ ៣%
- ពី ១៦ ឆ្នាំឡើងទៅ ទទួលបានសន្ទស្សន៍ ៤%
- ចំពោះសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងតំណែងបីអាណត្តិបន្តបន្ទាប់គ្នា ទទួលបានសន្ទស្សន៍ ៤%

ការគណនាប្រាក់សោធននិវត្តន៍ប្រចាំខែរបស់និវត្តជន ត្រូវអនុវត្តតាមរូបមន្ត ដូចខាងក្រោម៖

| | |
|---|---|
| ប្រាក់សោធននិវត្តន៍ប្រចាំខែ = | ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់យ៉ាង ក្នុងរយៈពេលមួយឆ្នាំនៃឆ្នាំណាមួយ ដែលមានចំនួនទឹកប្រាក់អតិបរមា x សន្ទស្សន៍ |

ប្រាក់សោធននិវត្តន៍ប្រចាំខែ អាចប្រែប្រួលបានទៅតាមប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់យ៉ាងនៃថវិកាប្រចាំឆ្នាំអតិបរមា ដោយមិនគិតជានិវត្តជនមុន ឬនិវត្តជនក្រោយឡើយ។

**មាត្រា ៦.-**

អតីតសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលមានអាយុក្រោម ៦០ ឆ្នាំ អាចស្នើសុំប្រាក់សោធននិវត្តន៍បាន នៅពេលមានអាយុគ្រប់ ៦០ ឆ្នាំ ដោយត្រូវបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ៣ នៃព្រះរាជក្រឹត្យនេះ។

**មាត្រា ៧.-**

និវត្តជនជាអតីតសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នៅពេលជាប់ជាតំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភា ឬសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មិនត្រូវបានបើកផ្តល់ប្រាក់សោធននិវត្តន៍ទេ។ សាមីជនត្រូវបើកប្រាក់បំណាច់ជាតំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភា ឬសមាជិកក្រុមប្រឹក្សាធម្មនុញ្ញជាធម្មតា ហើយនៅពេលចប់អាណត្តិ សាមីជនអាចសម្រេចសាជាថ្មីថាយកប្រាក់សោធននិវត្តន៍តំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភា ឬសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ឬប្រាក់សោធននិវត្តន៍សមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**មាត្រា ៨.-**

របៀបគិតអតីតភាពការងាររបស់សមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គឺមានដូចតទៅ៖

- ត្រូវរាប់បញ្ចូលអតីតភាពការងារជាសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នូវអតីតភាពការងារដែលនិវត្តជនបានធ្វើជាតំណាងរាស្ត្រ ឬ/និងសមាជិកព្រឹទ្ធសភា ឬ/និងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ
- មានអតីតភាព ចាប់ពី ១៦ ថ្ងៃឡើងទៅ ត្រូវគិតស្មើ ១ ខែ
- មានអតីតភាព ចាប់ពី ៦ ខែឡើងទៅ ត្រូវគិតស្មើ ១ ឆ្នាំ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## ជំពូកទី៣
## ប្រាក់ឧបត្ថម្ភមរណភាព

**មាត្រា ៩.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្ដល់ថវិកាចំនួន ៥០,០០០,០០០ (ហាសិបលាន) រៀល សម្រាប់រៀបចំពិធីបុណ្យសព ក្នុងករណីដែលសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទទួលមរណភាពនៅក្នុងអាណត្តិ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្ដល់ប្រាក់បំណាច់ ព្រមទាំងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់យ៉ាង ដល់គ្រួសារសពចំនួន ១២ ខែ របស់សមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលទទួលមរណភាពក្នុងអាណត្តិ។

ប្រាក់បំណាច់ ព្រមទាំងប្រាក់ឧបត្ថម្ភផ្សេងៗជូនដល់គ្រួសារសពក្នុងកថាខណ្ឌទី២ ខាងលើ អាចត្រូវបានបើកផ្ដាច់ ប្រសិនបើមានការស្នើសុំពីគ្រួសារសព។

**មាត្រា ១០.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្ដល់ប្រាក់ឧបត្ថម្ភមួយលើក ចំនួន ១២ ខែ លើប្រាក់សោធននិវត្តន៍សរុបប្រចាំខែរបស់សាមីជន ដល់គ្រួសារសពនៃនិវត្តន៍ជនសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

## ជំពូកទី៤
## ភារកិច្ច និងសមត្ថកិច្ចគ្រប់គ្រងប្រាក់សោធននិវត្តន៍ និងប្រាក់ឧបត្ថម្ភមរណភាព

**មាត្រា ១១.-**

ជារៀងរាល់ឆ្នាំ ក្រោមការណែនាំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលើកគម្រោងផែនការស្ថិតិ និងថវិកាប្រាក់សោធននិវត្តន៍ និងប្រាក់ឧបត្ថម្ភមរណភាពសម្រាប់សមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលគ្រប់លក្ខខណ្ឌចូលនិវត្តន៍ និងទទួលមរណភាព ដើម្បីដាក់ឆ្លងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតពិនិត្យ សម្រេចបញ្ចូលក្នុងថវិកាប្រចាំឆ្នាំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ១២.-**

ការបើកប្រាក់សោធននិវត្តន៍ និងប្រាក់ឧបត្ថម្ភមរណភាពរបស់សមាជិក សមាជិកា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាសមត្ថកិច្ចអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា ១៣.-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត/១១១៧/១១៤៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**ហត្ថលេខា**
**ស៊ិក ប៊ុនហុក**

លេខៈ ១១០៤ ស.ណ
**សំណៅដែលមានអង្គលេខាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**